MGCC
MASSACHUSETTS GROWTH CAPITAL CORPORATION
EMPOWERING SMALL BUSINESS

# កម្មវិធីជំនួយថវិកា BIZ-M-POWER

## ហេតុអ្វីបានជាយើងកំពុងដាក់ឱ្យប្រើប្រាស់កម្មវិធីជំនួយថវិកានេះ?

MGCC ប្តេជ្ញាជួយដល់សហគ្រិនដែលមិនសូវទទួលបានជំនួយ និងម្ចាស់អាជីវកម្មខ្នាតតូចនៅរដ្ឋ Massachusetts ឱ្យទទួលបានជោគជ័យផ្នែកសេដ្ឋកិច្ច។កម្មវិធីនេះផ្តោតលើការជួយដល់សហគ្រិនដែលមានប្រាក់ចំណូលទាប និងមធ្យមជាមួយនឹងការទទួលបានការពង្រីក ការកែលម្អ ឬជួលទីតាំង ការទិញ ឬជួលឧបករណ៍ ឬជាមួយនឹងការបំពេញនូវតម្រូវការដើមទុនផ្សេងទៀតនៃអាជីវកម្មតាមរយៈការប្រមូលមូលនិធិ។

គោលបំណងរបស់ Biz-M-Power គឺដើម្បីផ្តល់ឱ្យសហគ្រិននូវចំណេះដឹង និងជំនាញថ្មីៗសម្រាប់ការរីកលូតលាស់អាជីវកម្មរបស់ពួកគេ និងឆ្ពោះទៅរកវិធីសាស្រ្តប្រកបដោយភាពច្នៃប្រឌិតដើម្បីទទួលបានដើមទុនតាមរយៈការគាំទ្រដែលទទួលបានពីប្រជាជនក្នុងតំបន់ ក្នុងសង្កាត់ សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ។

Biz-M-Power មានពីរដំណាក់កាលសម្រាប់ផ្តល់សិទ្ធិអំណាចដល់ម្ចាស់អាជីវកម្មខ្នាតតូច និងសហគ្រិននៅរដ្ឋ Massachusetts ដើម្បីទទួលបានភាពជោគជ័យផ្នែកសេដ្ឋកិច្ច។គោលដៅគឺដើម្បីជម្រុញភាពជោគជ័យខាងផ្នែកសេដ្ឋកិច្ចរបស់ម្ចាស់អាជីវកម្មខ្នាតតូចនៅរដ្ឋ Massachusetts តាមរយៈការគាំទ្រសម្រាប់ការបង្កើនដើមទុន / ភាគហ៊ុនសម្រាប់អាជីវកម្មដែលដាក់ពាក្យសុំប្រាក់ជំនួយពី Biz-M-Power ។ដំណាក់កាលដំបូងគឺត្រូវអនុវត្តចំពោះកម្មវិធីដែលតម្រូវឱ្យមានភាពជាដៃគូជាមួយអង្គការមកពីបណ្តាញរបស់ MGCC អ្នកផ្តល់ជំនួយបច្ចេកទេស (Small Business Technical Assistance) (SBTA)

ដែលនឹងធ្វើជាអ្នកឧបត្ថម្ភដល់អ្នកដាក់ពាក្យ។ដំណាក់កាលទីពីរ ការរង់ចាំការអនុម័តពាក្យសុំរបស់ MGCC និងការយល់ព្រមពី Patronicity នឹងត្រូវប្រើប្រាស់វេទិការបស់មូលនិធិ Patronicity ដើម្បីជួយដល់សហគមន៍ និងបង្កើនថវិកាដើម្បីឆ្លើយតបទៅនឹងចំនួនទឹកប្រាក់ដែលបានស្នើសុំនៅក្នុងពាក្យសុំជំនួយរបស់ពួកគេ។

តាមរយៈថវិកាសរុប $7,500,000 ដែលបម្រុងទុកពីថវិកាប្រតិបត្តិការរបស់ Commonwealth សម្រាប់ឆ្នាំសារពើពន្ធ 2021 (FY21) ការផ្តល់ជំនួយឥតសំណងរហូតដល់ $20,000 មានសម្រាប់ឱកាសនេះដើម្បីយុទ្ធនាការប្រមូលមូលនិធិដោយជោគជ័យ។អាទិភាពត្រូវបានផ្តល់ជូនដល់អាជីវកម្មខ្នាតតូចដែលមានហាងដែលគ្រប់គ្រងដោយស្ត្រី ជនជាតិភាគតិច ជនអន្តោប្រវេសន៍ អ្នកនិយាយភាសាអង់គ្លេសដែលមិនមែនជាជនជាតិដើម អតីតយោធាអាមេរិក ជនពិការ សមាជិកសហគមន៍ LGBTQ+ និងអាជីវកម្មដែលកំពុងប្រតិបត្តិការនៅក្នុងច្រកចេញចូលទីក្រុងនៃរដ្ឋ Massachusetts ។

## តើកម្មវិធីជំនួយថវិកានេះគឺជាអ្វី?

កម្មវិធីជំនួយថវិកានេះនឹងផ្តល់នូវការផ្តល់ជំនួយឥតសំណងរហូតដល់ $20,000 (ដក $250 ដែលត្រូវបង់ទៅអ្នកឧបត្ថម្ភ SBTA) នៅក្នុងមូលនិធិដើម្បីបន្តគម្រោងដែលនឹងជួយអាជីវកម្មខ្នាតតូចក្នុងសង្គម និងបុគ្គលដែលជួបការលំបាកផ្នែកសេដ្ឋកិច្ចទទួលបានមូលនិធិតាមរយៈវេទិការដ៏ច្រើន។អ្នកផ្តល់សេវា SBTA នឹងឧបត្ថម្ភនិងជួយដល់អាជីវកម្មខ្នាតតូចក្នុងការចូលនិងបំពេញដំណើរការដាក់ពាក្យស្នើសុំ។អ្នកដាក់ពាក្យសុំអាជីវកម្មខ្នាតតូចដោយមានជំនួយពីអ្នកឧបត្ថម្ភ SBTA របស់ពួកគេ ហើយប្រសិនបើត្រូវបានយល់ព្រមសម្រាប់ជំហានបន្ទាប់ នឹងមានគ្រូបង្វឹករបស់ Patronicity ក្នុងការជួយគម្រោងប្រមូលមូលនិធិរបស់ពួកគេ។

## តើអ្នកណាខ្លះមានសិទ្ធិដាក់ពាក្យស្នើសុំបាន?

ត្រូវតែជា **សហគ្រិន ឬ អាជីវកម្មខ្នាតតូចដែល៖**

- **គឺ** មានមូលដ្ឋាននៅរដ្ឋ Massachusetts ជាមួយនឹងការបង្កើតហាង (រូបវន្ត) ដែលកំពុងដំណើរការប្រតិបត្តិការនៅក្នុងរដ្ឋ Massachusetts
- **គឺ** ជួលនិយោជិកធ្វើការពេញម៉ោងចន្លោះពី 1 ដល់ 20 នាក់ រួមបញ្ចូលម្ចាស់អាជីវកម្ម 1 ឬច្រើននាក់
- **គឺ**ជាប្រភពចំណូលចម្បងរបស់ម្ចាស់អាជីវកម្ម
- **មាន** ប្រាក់ចំណូលប្រចាំឆ្នាំមិនលើសពី $2,500,000
- **ត្រូវបាន** ជ្រើសរើសដោយអ្នកផ្តល់ជំនួយបច្ចេកទេស (Technical Assistance Provider) តាមរយៈកម្មវិធីជំនួយបច្ចេកទេសសម្រាប់អាជីវកម្មខ្នាតតូច (Small Business Technical Assistance Program) របស់ MGCC
- **ត្រូវបាន** បង្កើតឡើងដោយស្របច្បាប់ / ក្នុងដំណាក់កាលដំបូងនៃប្រតិបត្តិការអាជីវកម្មយ៉ាងតិច 3 ខែ
- **គឺ <u>មិនមែន</u>** ជាអង្គការមិនស្វែងរកប្រាក់ចំណេញ អង្គការមិនរកប្រាក់ចំណេញ ឬអង្គការសប្បុរស
- **គឺ <u>មិនមែនជា</u>** អាជីវកម្មជួញដូរផ្តាច់មុខ (franchise) ដែលមានទីតាំងច្រើនជាង 2 កន្លែង រួមទាំងទីតាំងនិងអាជីវកម្មដែលគ្រប់គ្រងដោយឯកជន (អាជីវកម្មជួញដូរផ្តាច់មុខដែលមានរហូតដល់ 2 ទីតាំងនឹងត្រូវយកមកពិចារណា)
- **គឺ <u>មិនមែនជា</u>** អាជីវកម្មជួល/លក់អចលនទ្រព្យ
- **គឺ <u>មិនមែនជា</u>** អ្នកបញ្ចុះបញ្ចូលខាងនយោបាយ
- **គឺ <u>មិនមែនជា</u>** អាជីវកម្មទាក់ទងនឹងកញ្ឆា

**ជាកម្មសិទ្ធិរបស់៖**

- បុគ្គលដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅពេលដាក់ពាក្យស្នើសុំ

- ពលរដ្ឋអាមេរិកឬអ្នករស់នៅអចិន្ត្រៃយ៍

## តើកម្មវិធីនេះនឹងត្រូវចាប់ផ្តើមបើកនៅពេលណា?

កម្មវិធីជំនួយនេះនឹងចាប់ផ្តើមបើកនៅថ្ងៃទី 15 ខែមិថុនាឆ្នាំ 2021 ។នេះគឺជាការដាក់ពាក្យជាដំណាក់កាលដោយការដាក់ពាក្យស្នើសុំជំនួយថវិកានឹងត្រូវបានត្រួតពិនិត្យជារៀងរាល់ខែ។ កាលបរិច្ឆេទផុតកំណត់ទី 1 គឺថ្ងៃទី 2 ខែសីហា ឆ្នាំ 2021 ។

## តើខ្ញុំដាក់ពាក្យស្នើសុំដោយរបៀបណា?

អ្នកដាក់ពាក្យទាំងអស់ត្រូវតែទទួលបានការឧបត្ថម្ភពីអ្នកផ្តល់ជំនួយបច្ចេកទេសតាមរយៈកម្មវិធី SBTA របស់ MGCC ។សម្រាប់តារាងឈ្មោះអ្នកផ្តល់សេវាកម្ម SBTA របស់យើងសូមចុចត្រង់នេះ៖
https://www.empoweringsmallbusiness.org/fy2021-awardees

*សូមស្វែងរកឯកសារពេញលេញរបស់ RFP សម្រាប់ព័ត៌មានបន្ថែមអំពីពាក្យស្នើសុំ លក្ខខណ្ឌប្រើប្រាស់ថវិកាដែលបានអនុម័តយល់ព្រម និងព័ត៌មានលម្អិតបន្ថែមនៅលើគេហទំព័ររបស់យើង៖ https://www.empoweringsmallbusiness.org/empowerdigital*